
Kids of Destiny
Reaching the Next Generation
www.kidsofdestiny.org

## 4.10 ព្រះយេស៊ូវស្រលាញ់ក្មេងៗ

នៅថ្ងៃមួយ ព្រះយេស៊ូវទ្រង់កំពុងបង្រៀននៅកន្លែងមួយ ដែលហៅថាស្រុកយូដា។ មានមនុស្សមួយក្រុមធំបានប្រមូលគ្នាមកស្តាប់ទ្រង់មានបន្ទូល ។ ព្រះយេស៊ូវទ្រង់ទម្លាប់នឹងរឿងនេះទៅហើយ! ទ្រង់សព្វព្រះទ័យក្នុងការបង្រៀនមនុស្សមួយក្រុមនេះផងដែរ។

ពួកផារីស៊ីក៏នៅទីនោះដែរ។ ពួកគេជាក្រុមមនុស្ស ដែលមិនចូលចិត្តព្រះយេស៊ូវ។ ពួកគេបានសួរគាត់នូវសំណួរពិបាកៗ ដែលពួកគេគិតថា ទ្រង់មិនអាចឆ្លើយបាន។ ព្រះយេស៊ូវទ្រង់មានព្រះបន្ទូលឆ្លើយនូវសំណួរទាំងអស់ ។ ពួកគេមិនអាចប្រកែកជាមួយទ្រង់បានទេ ពីព្រោះចម្លើយរបស់ទ្រង់ច្បាស់ណាស់។ វាធ្វើឱ្យពួកគេកាន់តែខឹងនឹងទ្រង់។

ក្នុងកំឡុងពេលបង្រៀននេះ មនុស្សជាច្រើន ចង់ឲ្យព្រះយេស៊ូវដាក់ព្រះហស្តលើកូនៗរបស់ពួកគេ ។ ពួកគេដឹងថា ព្រះយេស៊ូវទ្រង់ពិតជាពិសេសណាស់ ដូច្នេះ ប្រសិនបើទ្រង់ដាក់ព្រះហស្តលើកូនៗរបស់ពួកគេ នោះក្មេងៗនឹងទទួលបានព្រះពរ។ ប្រហែលជាពួកគេ អាចនឹងត្រូវបានជាសះស្បើយពីជម្ងឺផងដែរ។ ប្រហែលជាពួកគេនឹងមានចិត្តល្អចំពោះគ្នាទៅវិញទៅមក។ ប្រហែលជាពួកគេនឹងរស់នៅក្នុងជីវិតល្អ ហើយបម្រើព្រះ។ មិនថាពួកគេកំពុងគិតអំពីហេតុផលអ្វីក៏ដោយ មនុស្សជាច្រើនបាននាំកូនៗ របស់ពួកគេ មករកព្រះយេស៊ូវ ។

ពួកសិស្សគិតថា នេះជាការខ្ជះខ្ជាយពេលវេលារបស់ព្រះយេស៊ូវ។ ពួកគេបាននិយាយទៅកាន់ឪពុកម្តាយហើយប្រាប់ពួកគេឲ្យត្រឡប់ទៅវិញ កុំរំខានព្រះយេស៊ូវដោយនាំកូនៗរបស់ពួកគេ មករកទ្រង់ទៀតឡើយ។ ប៉ុន្តែនៅពេលដែលព្រះយេស៊ូវបានឃើញដូច្នេះ ទ្រង់មិនសព្វព្រះទ័យនឹងអ្នកដើរតាមទ្រង់ទេ។ ទ្រង់ដឹងថា ពួកគេខុសហើយ ក្នុងការឲ្យក្មេងៗនៅឆ្ងាយពីទ្រង់ ។ បន្ទាប់មក ព្រះអង្គមានព្រះបន្ទូលទៅកាន់សិស្សថា៖ «ទុកឲ្យក្មេងៗមកឯខ្ញុំចុះ កុំឃាត់ពួកគេអី! ព្រោះនគររបស់ព្រះជាកម្មសិទ្ធិរបស់មនុស្ស ដែលមានចិត្តដូចជាក្មេងៗ។ កុមារងាយជឿ ងាយទុកចិត្ត ងាយនឹងស្រលាញ់។ ព្រះយេស៊ូវបានមានបន្ទូលប្រាប់ពួកគេថា បើពួកគេមិនជឿ និងទទួលយកនគររបស់ព្រះដូចក្មេងតូចទេ ពួកគេនឹងមិនអាចចូលនគរព្រះបានឡើយ។

ហេតុដូច្នេះហើយព្រះយេស៊ូវបានបន្តស្វាគមន៍ក្មេងៗ។ ទ្រង់បានទទួលពួកគេដោយព្រះហស្តទ្រង់ ដូចជាម៉ាក់ប៉ាធ្វើ ឬដូចជាជីដូនជីតាយើងធ្វើអញ្ចឹង។ ទ្រង់បានលើកពួកគេឡើង។ ទ្រង់បានបង្ហាញពួកគេថា ទ្រង់ស្រឡាញ់ពួកគេខ្លាំងណាស់។ បន្ទាប់មក ទ្រង់ដាក់ព្រះហស្តលើពួកគេ ហើយប្រទានពរដល់ពួកគេ។ នោះពិតជាពេលវេលាដ៏ពិសេសមួយ មិនត្រឹមតែសម្រាប់កុមារប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់ឪពុកម្តាយផងដែរ។

ព្រះយេស៊ូវទ្រង់ស្រឡាញ់ក្មេងៗ ហើយព្រះយេស៊ូវស្រឡាញ់អ្នក ។

**ម៉ាកុស ១០**

4.10 **ព្រះយេស៊ូវស្រលាញ់ក្មេងក្មេង - សេចក្តីណែនាំសម្រាប់គ្រូបង្រៀន**

**កំណត់សំគាល់**

១) ជាថ្មីម្តងទៀត ព្រះយេស៊ូកំពុងបង្រៀនដល់ក្រុមមនុស្សជាច្រើន។ ពួកគេដឹងថាទ្រង់មានរឿងសំខាន់ៗ ដើម្បីប្រាប់ពួកគេ។ ពួកគេចង់រៀនអ្វីទាំងអស់ ដែលទ្រង់ត្រូវបង្រៀន។ ប៉ុន្តែក៏មានអ្នកផ្សេងទៀតនៅទីនោះ ដែលមិនយល់ស្របនឹងអ្វី ដែលព្រះយេស៊ូវទ្រង់កំពុងធ្វើនោះដែរ។ ពួកគេជាមនុស្សខាងសាសនា ដែលគេហៅថាគណៈផារិស៊ី។ ពួកគេចង់សួរសំណួរណា ដែលពួកគេគិតថាទ្រង់មិនអាចឆ្លើយបាន។ គឺពួកផារិស៊ីចង់បញ្ជាក់ថា ពួកគេឆ្លាតជាងព្រះយេស៊ូវ ។

២) ឪពុកម្តាយចង់នាំកូនៗរបស់ពួកគេ មករកព្រះយេស៊ូវ ដើម្បីឲ្យព្រះអង្គប្រទានពរដល់ពួកគេ។ វាជារឿងសំខាន់ណាស់ចំពោះឪពុកម្តាយនៅទីនោះ។ ប្រហែលជាមានក្មេងៗច្រើនណាស់។ តើព្រះយេស៊ូវទ្រង់អាចឲ្យពរដល់ពួកគេទាំងអស់គ្នាទេ? ត្រូវហើយ វាជាអ្វីដែលទ្រង់ចង់ធ្វើ ។

៣) សិស្សព្យាយាមរារាំងឪពុកម្តាយ មិនឱ្យនាំកូនៗរបស់ពួកគេមកឡើយ។ ព្រះយេស៊ូវទ្រង់ខឹងនឹងពួកសិស្ស។ ទ្រង់បានប្រាប់ពួកគេឱ្យនាំក្មេងៗមករកឯទ្រង់។ ទ្រង់មានព្រះបន្ទូលថា មនុស្សគ្រប់រូបចាំបាច់ត្រូវមានចិត្តដូចក្មេងតូច ដើម្បីចូលទៅក្នុងនគររបស់ព្រះបាន។

**សំណួរ:**

១) តើក្រុមមនុស្សណា ដែលមិនយល់ស្របនឹងព្រះយេស៊ូវ?

២) តើឪពុកម្តាយចង់ធ្វើអ្វី?

៣) តើសិស្សបានធ្វើអ្វីខ្លះ?

៤) តើព្រះយេស៊ូវមានបន្ទូលអ្វីខ្លះ ទៅកាន់ពួកសិស្ស?

៥) តើព្រះយេស៊ូវបានធ្វើអ្វី?

**ចម្លើយ:**

១) ពួកផារិស៊ី មិនយល់ស្របនឹងព្រះយេស៊ូវទេ។

២) ពួកគេចង់នាំកូនៗ របស់ពួកគេមករកព្រះយេស៊ូវ។

៣) ពួកគេបានព្យាយាមហាមឪពុកម្តាយ មិនឱ្យនាំកូនៗរបស់ពួកគេ មករកព្រះយេស៊ូវ។

៤) ព្រះយេស៊ូវបានមានបន្ទូលប្រាប់ពួកសិស្ស ឱ្យនាំក្មេងៗមករកទ្រង់។

៥) ព្រះយេស៊ូវទ្រង់ឱបកូនក្មេង ហើយប្រទានពរដល់ពួកគេ។



Kids of Destiny
Reaching the Next Generation
www.kidsofdestiny.org